BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K_1
1942 (10)

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ១០

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៥
គ.ស. ១៩៤២

# បញ្ជីរឿង

ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ១៣ ព្រះត្រៃវិនយធម្ម ហ៏-ជា ក្រុមជំនុំព្រះត្រៃបិដក សំដែង . . . . . . . . . . . . . . . . . . . . . . . . ១

២ — ច្បាប់ផ្សេង ៗ ភាគ ៤ :

១) ច្បាប់មហានេតិ ភជសួស្តី . . . . . . . . . . . . . . . . . . . . ១០

២) ល្បើកច្បាប់ក្រិត្យក្រម . . . . . . . . . . . . . . . . . . . . . ២៧

៣ — ប្រវត្តិពួកឧបាសិកា ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់ :

៥) នាងឧត្តរា - នន្ទមាតា . . . . . . . . . . . . . . . . . . . . ៤៥

៦) នាងសុប្បវាសា - កោលិយធីតា . . . . . . . . . . . . . . . . ៤៧

៤ — រឿងព្រះបាទអសោក អ្នកអាចារ្យ គីម - អាន ប្រែនិងរៀបរៀង (តមក) . ៥០

៥ — ពង្សាវតាររោម ស្រង់យកអំពីគោលបារាំងផ្សេង ៗ ក្នុងពង្សាវតារលោក (តមកនឹងចប់) . . . . . . . . . . . . . . . . . . . . . . . . ៦៦

៦ — ភូមិសាស្ត្រសង្ខេប នៃទ្វីបអូស្ត្រាលី . . . . . . . . . . . . . . . . ៧៣

វិទ្យុធម្មទេសនា កណ្ឌទី ១៣

# ព្រះគ្រិនយធម្ម ហ៊ី-ជា ក្រុមជំនុំព្រះត្រៃបិដក

សំដែងនៅថ្ងៃសុក្រ ១៥ កើតខែជេស្ឋ ឆ្នាំមមីចត្វាស័ក ពុទ្ធសករាជ ២៤៨៥

ត្រូវនឹងថ្ងៃ ២៩ ម៉េ ឆ្នាំ ១៩៤២ ។

វេលានេះ អាត្មាភាពនឹងសំដែងធម្មកថា ពណ៌នាព្រះសទ្ធម្មដែលជាពាក្យប្រដៅរបស់ព្រះដ៏មានព្រះភាគ តាមអភិលិខិតសម័យ ដែលត្រូវវេនមកដល់អាត្មា ដោយលំដាប់ ដើម្បីជាផ្លូវចំរើនសតិបញ្ញា និងសម្មាបដិបត្តិ នៃពុទ្ធមាមកបរិស័ទទាំងឡាយ ។

ធម្មទេសនានេះ អធិប្បាយផ្លូវធម៌ផែបផ្លូវលោក គឺសេចក្ដីជាអ្នកអង់អាច ក្នុងករណីយកិច្ចតូចធំទាំងពួង គឺប្រកបដោយសេចក្ដីពិចារណាស្ទង់មើលដោយឧបាយដ៏ប្រពៃ ហើយទើបចាត់ធ្វើដំណើរកិច្ចានុកិច្ចនោះៗ ឲ្យផុះដាលជាផលល្អ តាមដែលត្រូវការរបស់ខ្លួន របស់អ្នកដទៃ រហូតដល់ទៅជាតិ សាសនា មហាក្សត្រ ស្រុកទេសរបស់ខ្លួន ។

សំដែងសមគ្គទេសនា គឺសេចក្ដីជាអ្នកអង់អាច សមគ្គទេសនានេះ មានសេចក្ដីទូលាយណាស់ ទើបគួរប្រមូលកំណត់ចុះឲ្យនៅក្នុងរង្វង់ តាមដែលត្រូវការដូច្នេះគឺ:

១ អាចសមតាមអត្តភាព

២ អាចសមតាមដំណែងមុខការ

៣ អាចសមតាមពួកគណៈ

៤ អាចសមតាមធម៌ ៗ

សេចក្តីអធិប្បាយក្នុងសមត្ថទាំង ៤ យ៉ាងនេះគឺ:

១ – ការដែលតាំងខ្លួនបានជាបុគ្គលស្អុកស្អមម៉ាំមួន ឈ្មោះថាអាចសមតាមអត្តភាព; ដោយសេចក្តីគិតស្គាល់ដំឡៃរបស់ខ្លួនមានដើមថា មានជាតិដូចម្តេច មានត្រកូលដូចម្តេច មានភេទដូចម្តេច មានយសស័ក្តិត្រឹមណា ក៏អាចតាំងខ្លួនឲ្យសមតាមនោះ ចាប់ដើមតាំងតែជាអ្នកសុភាពកបសា តែជាអ្នកអង់អាចក្លាហាន ក្នុងករណីយកិច្ចតូចធំ មិនជាក់ធុរៈព្យាយាម ប្រឹងធ្វើចាល់តែសម្រេចមកបាន ៗ មនុស្សដែលទន់ជាបំផុត មិនអាចទ្រាំតាំងខ្លួនឯងបាន ទើបមិនសមគួរនឹងប្រព្រឹត្តដូច្នោះ សូម្បីក្នុងខណៈធ្វើករណីយកិច្ច ប្រសិនបើមានឧបសគ្គមកជំទាស់ ក៏មិនគួរនឹងរេរាចិត្តធុញថប់ចុះចាញ់ង៉ាយៗ តោងប្រឹងប្រយ័ត្នកុំឲ្យខូចការ តាំងចិត្តកណាត់ប៉ុនប៉ងធ្វើរឿយៗទៅកុំឈប់ ធ្វើដំណើរចិត្តឲ្យរីកក្នុងសេចក្តីមិនប្រមាទ ហើយថ្នមរក្សាចិត្តនោះទុកចាល់តែអាចដកខ្លួនឲ្យផុតឧបសគ្គនោះជាជាន់ៗ រហូតដល់ជាន់ទីបំផុត ប្រៀបដូចជាឆ្កែទន់ដែលឧស្សាហ៍

វិទ្យុធម្មទេសនាគាថាទី ៤

# ព្រះបាឡាត់ឃោសនាគ អាចារ្យសាលាបាលីជាន់ខ្ពស់ សំដែង

ថ្ងៃអង្គារ ៨ កើតខែចេត្រឆ្នាំម្សាញ់ត្រីស័ក ព. ស. ២៤៨៥ (៩ - ៣ - ៤២)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការព្រះអរហំសម្មាសម្ពុទ្ធគតវន្តមុនីព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃដោយសេចក្ដីគោរព ។

លំដាប់នេះនឹងសំដែងអំពីកំណើតនៃសេចក្ដីសុខជាសង្ខេបតាមកាលវេលា ដូចតទៅនេះ ។

សុខោ ពុទ្ធានមុប្បាទោ ការបានត្រាស់ដឹងឡើងនៃព្រះពុទ្ធគ្រប់ព្រះអង្គជាហេតុនាំឲ្យកើតសេចក្ដីសុខ (ជាច្រើនប្រការដល់សព្វសត្វក្នុងត្រៃលោក) ។

អធិប្បាយថា ក្នុងកាលណាមួយៗ, ដែលមានព្រះអរហន្តសម្មាសម្ពុទ្ធបានត្រាស់ដឹងឡើង, កាលនោះសត្វមានចំនួនច្រើនរាប់មិនអស់ តែងបានជួបប្រទះនឹងប្រយោជន៍ សេចក្ដីសុខស្ងប់ដ៏ក្រៃលែង ។ ព្រោះព្រះអង្គឧប្បត្តិកើតឡើងទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរស្ងើច ជាទីបូជារបស់ពួកជនជាមនុស្ស ហើយបរិបូរដោយចំណេះវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានព្រះទ័យពេញព្រៀបដោយសេចក្ដីករុណា អាណិត

ការសួរទៅរកពួកសត្វឲ្យទៅក្នុងត្រៃភពផុតរំសេមុទ ។ ព្រះពិជិតមារបរមគ្រូ ដែលទ្រង់បានចួបប្រទះនឹងសេចក្តីសុខក្សេមក្សាន្តខ្ពស់ផុតចំណោមមនុស្ស ដោយគោត្រត្រកូល ភពសម្បត្តិជាដើម ក៏ព្រោះតែកម្រៃបុណ្យ សេចក្តីល្អដែលទ្រង់បានកសាងសន្សំទុកជាលំដាប់ជាតិតៗមកដោយពិត ។

មហាការុណិកោ ណាថោ ព្រះលោកនាថប្រកបដោយមហាករុណាគុណ ពោះព្រះអង្គបានសេចក្តីសុខស្រួលដូចម្តេច ក៏មិនទម្រន់ឲ្យលក់ផ្ទក់ងប់ជាប់ព្រះទ័យឲ្យទាល់តែលង់គាំងគំនិតដល់ភ្លេចនឹកមិនឃើញការសុខទុក្ខរបស់ពួកសត្វដែលលិចលង់ក្នុងលោកសន្និវាសនេះទេ, ព្រះអង្គមិនព្រមសុខព្រះទ័យទទួលសោយសេចក្តីសុខចំរើនជាផលសំណាងដែលបានមកតាំងនៅស៊ប់ក្នុងកណ្តាប់ព្រះហស្តរបស់ព្រះអង្គ តែមួយព្រះអង្គប៉ុណ្ណោះ. ទ្រង់ស៊ូលះបង់ប្រយោជន៍តាំងនោះចោលស្រឡះមិននឹកនា ទំប្រឹងបំពេញព្យាយាមទាល់តែបានសម្រេចប្រាជ្ញាពោធិញាណលើគេឧបល័ក្ខ ព្រះអង្គបានទីជាសត្ថនាយកៈ អ្នកដឹកនាំស្រោចស្រង់សត្វទាំងឡាយឲ្យទៅក្នុងលោកុឲ្យផុតពីសេចក្តីទុក្ខលំបាកមាន កើត, ចាស់, ឈឺ, ស្លាប់ជាដើម (ដូចជាសំពៅធំធេង) ។

តាប់ដើមតាំងពីត្រឹមថ្ងៃដែលទ្រង់បានត្រាស់ដឹងមកទល់នឹងថ្ងៃដែលទ្រង់យាងត្រឡប់ពីដើមកែសខាងត្បូងដើមពោធិព្រឹក្ស មកគង់នៅក្រោមម្លប់ដើមជ្រៃ ជាខាងកើតដើមពោធិព្រឹក្សវិញ នៅក្នុងរវាងពី ៤១ ទៅ

ទល់នឹង ៤៦ ថ្ងៃ ។ តពីនោះមក ព្រះអរហំសម្ពុទ្ធ ស្ដេចយាងប្រកាសសាសនា ប្រទានឱវាទពាក្យប្រៀនប្រដៅណែនាំពួកសត្វមានមនុស្សនិងទេវតាជាដើម, ទំព្រឹងព្យាយាមសំដែងធម៌បំភ្លឺពន្យល់ប្រាប់គុណ, ទោស, ខុស, ត្រូវ ឲ្យសត្វយល់ឃើញពិតៗ ឥតរួញរានឹងសេចក្ដីនឿយព្រួយព្រះកាយពលកម្មការប្រកាសប្រាប់ប្រយោជន៍ដល់សត្វទាំងនោះឡើយ ។ ព្រះអង្គទ្រង់ប្រឹងបំពេញពុទ្ធកិច្ចគ្រប់គ្រាន់មិនមានចន្លោះ សមស័ក្ដិព្រះអង្គជាសត្ថានាយក អ្នកដឹកនាំស្រោចស្រង់ជាទីពឹងពំនាក់អាស្រ័យនៃសត្វក្នុងត្រៃលោកមែនៗ ទាំងមានព្រះអរិយាបថស្រគត់ស្រគំសមរម្យ, មានព្រះអធ្យាស្រ័យក៏ទន់ភ្លន់ស្មោះស្មើ ស្លូតត្រង់ទៅរកសត្វទូទៅ, គួរតាប់ចិត្តល្មមឲ្យមនុស្សទេវតានិងសត្វគ្រប់ថ្នាក់ទាំងទាប- ខ្ពស់មានសេចក្ដីសង្ឃឹមកក់ក្ដៅចូលទៅជ្រកកោនក្រោមម្លប់ពោធិសម្ភារបានសម្រេចសន្តិសុខតាមប្រាថ្នា; ព្រះអង្គមានទំនងគួរឲ្យសត្វក្នុងសាកលលោកគោរពក្រាបសំពះយកគម្រាប់តាមដោយសេចក្ដីពេញចិត្តមិនបាច់បង្ខំ ។

ព្រះពុទ្ធគុណដែលរៀបរាប់ដោយសង្ខេបមកខាងលើនេះ បើពោលបំព្រួញឲ្យខ្លីឆាយចំណាំជាងនោះមកទៀតថា: ព្រះអរហំសម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់មានព្រះទ័យស្អាត មិនប្រឡាក់ដោយបាបសេចក្ដីអាក្រក់ណាមួយ ហៅថា វិសុទ្ធិគុណ, ទ្រង់ទំព្រឹងបំពេញប្រយោជន៍ឲ្យសត្វបានទទួលសេចក្ដីសុខតាមគតិលោកគតិធម៌ស្មើៗគ្នា សមគួរដល់ភ័ព្វសំណាង

សត្វ  មិនលាក់បិទប្រយោជន៍ទុកសម្រាប់សោយសេចក្ដីសុខស្រួលតែមួយព្រះអង្គឡើយ  ហៅថា  ករុណាគុណ,  ទ្រង់មានឧបាយដ៏ប្រពៃក្នុងការទូន្មានសត្វ  ធ្វើសេចក្ដីជ្រៅឲ្យរាក់  កំបាំងឲ្យងាយយល់ងាយគិតជាដើម ហៅថា បញ្ញាគុណ ។ ដោយហេតុនេះទើបប្រាកដថាព្រះពុទ្ធគ្រប់ព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក  ជាហេតុនាំឲ្យបានសេចក្ដីសុខ (ដល់ពួកសត្វក្នុងត្រៃភព) ។

សេចក្ដីដែលសំដែងមកនេះ  ជាគុណដែលមានក្នុងព្រះអង្គ ។

ស្វាក្ខាតោ  ភគវតា  ធម្មោ  ធម៌ដែលព្រះភគវន្តសម្ពុទ្ធសំ-ដែងដោយប្រពៃ  មានគុណអាចស្រោចស្រង់ពួកសត្វលោកដែលពេញចិត្តកាន់តាមឲ្យផុតអំពីទុក្ខទោស  បានសេចក្ដីសុខស្រួលឃើញជាក់ច្បាស់ចំពោះមុខភ្លាមៗតាមជាក់តាមជាន់ឥតបង្អង់ចាំកាលវេលា ។ ធម្មោ សុចិណ្ណោ  សុខមាវហាតិ  ធម៌ដែលសត្វបានរក្សាទុកត្រឹមត្រូវនឹងផ្ដល់សេចក្ដីសុខមកឲ្យវិញពុំខាន ។

អធិប្បាយថា: អំពើល្អហៅថាធម៌, អ្នកប្រព្រឹត្តត្រូវតាមធម៌ ឈ្មោះថាបានរក្សាធម៌ទុកដោយប្រពៃ  នឹងត្រូវបានផលជាសុខ; អំពើអាក្រក់ហៅថាអធម៌  គឺមិនមែនធម៌; អ្នកមិនកាន់តាមធម៌  ឈ្មោះថាមិនរក្សាធម៌បែរទៅប្រព្រឹត្តអាក្រក់  ដែលមិនមែនជាធម៌  នឹងត្រូវបានផលជាទុក្ខ ។

រួមព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ហៅថា ពុទ្ធសាសនា ។

អស់លោក-អ្នកជាសាធុជនទាំងឡាយ ដែលពេញចិត្តគាប់អធ្យាស្រ័យ ចង់បានប្រយោជន៍ សេចក្ដីសុខចំរើន ត្រឹមតែក្នុងលោកនេះក្ដី ឬក៏ចង់ប្រាថ្នាដល់ទៅលោកខាងនាយទៀតផងក្ដី គួរតែប្រឹងខ្នៀតបង្អោនចិត្តចូលមកកាន់ព្រះពុទ្ធសាសនាចុះកុំខាន ព្រោះព្រះពុទ្ធសាសនានេះ អ្នកប្រាជ្ញជាន់ខ្ពស់ក្នុងលោកឃើញពិតថាជាសាសនាមានអានុភាព អាចធ្វើលោកឲ្យស្ងប់, ទាំងញ៉ាំងមនុស្សសត្វដែលទន់ទាបថោកថយឲ្យខ្ពង់ខ្ពស់ថ្លៃថ្នូរ, បើថ្លៃថ្នូរស្រាប់ ឲ្យរឹងរឹតតែវិសេសក្រៃលែងឡើងទៀត ។ សេចក្ដីដែលពណ៌នាមកនេះ ត្រង់តាមគោលដើមនៃពុទ្ធបំណងពិត; ព្រោះព្រះអង្គដែលទ្រង់ប្រឹងព្យាយាមសំដែងច្បាប់ប្រាប់ពន្យល់ មិនគិតនឿយហត់ទាំងម្ល៉េះ ដោយទ្រង់មានព្រះទ័យករុណា ចង់ស្រោយដោះពួកសត្វដែលជាប់ចំណងនៃសេចក្ដីទុក្ខលំបាកមានជាតិ, ជរា, ព្យាធិ, មរណជាដើមឲ្យរួចចាកទុក្ខបានសេចក្ដីសុខស្កប់ស្កល់ប៉ុណ្ណោះ ។ សូមអស់លោក-អ្នកស្ដាប់ៗហើយគំណត់ទុកក្នុងចិត្តចុះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្សសត្វកើតមកពេញទាំងសាកលលោក សុទ្ធសឹងតែប្រាថ្នាសេចក្ដីសុខខ្ពង់ខ្ពស់ថ្លៃថ្នូរគ្រប់ៗរូប, ដែលបែរជាបានសេចក្ដីគាប់ចុះទន់ទាប មិនសមដូចបំណងស្មើគ្នា

ទៅវិញនោះ បណ្ដាលមកពីហេតុច្រើនយ៉ាងណាស់, ខ្លះកើតឡើងដោយសេចក្ដីទន់ទាបក្រីក្រល្ងង់ខ្លៅស្រាប់មកពីកំណើតក៏មាន ព្រោះផលបុព្វតិប, ខ្លះកើតមកបានជួបប្រទះនឹងសេចក្ដីថ្កុំថ្កើងសម្បូណ៌សម្បត្តិគ្រប់គ្រាន់ស្រាប់ពីកំណើត តែធ្វេសក្រុបគិត ទម្រើសខ្លួនបណ្ដោយចិត្តឲ្យទៅប្រព្រឹត្តអាក្រក់ទាស់ទំនង ពានទៅលើអំពើមិនមែនជាធម៌ បានសេចក្ដីថ្លស់ធ្លោយធ្លាក់ខ្លួនជាអ្នកទន់ទាបអាប់ឱនថយទៅវិញក៏មាន ខ្លះទប់ខ្លួនឲ្យនៅត្រឹមតែស្មើៗមិនទាបមិនខ្ពស់ក៏មាន តាមសមគួរដល់អំពើដែលសត្វបានធ្វើរៀងខ្លួន ; ដូចពុទ្ធភាសិតថា សត្តេ កម្មំ វិភជ្ជតិ កម្មគឺអំពើដែលសត្វធ្វើទុកមកពីជាតិមុន ឬជាតិនេះ, ជាមេចំណែកចែកឲ្យសត្វបានសុខបានទុក្ខផ្សេងៗគ្នា មិនមែនអ្វីផ្សេងក្រៅពីអំពើរបស់ខ្លួននោះចែកឲ្យឡើយ ។

ឯអំពើអាក្រក់មិនត្រូវតាមផ្លូវធម៌ នាំមនុស្សឲ្យវិនាសបានសេចក្ដីទុក្ខលំបាកទាំងលោកនេះនិងលោកខាងមុខនោះដូច្នេះ ។

អបាយមុខ ហេតុនាំឲ្យវិនាសពាកសេចក្ដីចំរើន ៤ យ៉ាងគឺ:

១ - ឥត្ថីធុត្តៈ អ្នកជាកចិត្តជក់នឹងមាតុគ្រាម មិនមានចិត្តសន្ដោសត្រឹមតែភរិយា - ស្វាមីរបស់ផងខ្លួន ។

២ - សុរាធុត្តៈ អ្នកសេពគ្រឿងស្រវឹង

៣ - អក្ខធុត្តៈ អ្នកលេងល្បែងភ្នាល់

៤- បាបមិត្ត: អ្នកគប់គេមនុស្សអន្ធពាលអាក្រក់ជាមិត្ត ។

ហេតុទាំង ៤ នេះសុទ្ធសឹងតែជាអំពើអាក្រក់អាចនាំឲ្យប្រទេសជាតិ ភោគសម្ប័ទចំណេះវិជ្ជាចរិយាស្រកស្រុតចុះថោកទាប, នាំឲ្យវិនាសថ្លស់ ឃ្លាយខូចបង់ប្រយោជន៍សេចក្ដីសុខចំរើនរបស់មនុស្សគ្រប់សាកលលោក ជាក់ស្ដែងភ្លាមៗ; មិនបាច់ពោលថ្វីដល់ទៅលោកខាងមុខនោះឡើយ ។ មែនពិត, អំពើទាំងនេះ, បើសត្វខំប្រឹងប្រព្រឹត្តជាប់មិនលែង, លោក ពោលថា ទុកដូចជាយកគប់ភ្លើងយ៉ាងធំមកដុតកេលកំឡោចបំផ្លាញភោគ-សម្ប័ទ ចំណេះវិជ្ជា ចរិយា មារយាទ ជាតិកំណើតនិងសន្តិសុខដ៏រុងរឿង របស់ខ្លួនឲ្យខ្ទេចក្រិនខូចលែងលូតលាស់ដុះចំរើនឡើងទៀតរួច ចេះតែ រេចរិលចុះទៅជាទិច្ច ឈ្មោះថាជាមនុស្សជួញទុក្ខ ។

សាធុជនជាសប្បុរសគួរកុំប្រព្រឹត្តអំពើទាំងនេះឲ្យសោះ, កាលបើ សាធុជនបានវៀរចាកអំពើទាំងនេះរួចស្រឡះហើយ ឈ្មោះថាបានប្រ-ព្រឹត្តធម៌រក្សាធម៌ទុកដោយប្រពៃ នឹងបានផលជាសុខច្រើនប្រការ; បើ ពោលដោយសង្ខេបវិញគឺ: ១- សុខព្រោះមានចិត្តស្រះស្រួលស្មោះស្ម័ ទៅរកភរិយា-ស្វាមី ដោយមិនជាប់ចិត្តនឹងស្ដ្រីបុរសឯទៀត; ២- សុខ ព្រោះមានសំដីពិសាជាប្រក្រតី, មិននិយាយឡេះឡោះកកៃកករករឿង ឈ្លោះមិនខូចបង់ប្រាក់កាសដោយហេតុមិនសេពសុរា; ៣- សុខព្រោះ បានធ្វើការងារចំរើន រៀនវិជ្ជាចេះចាំមិនភ័យនឹងអ្នករាជការចាប់ចងឃុំឃាំង

លក់ត្នៃដោយហេតុមិនលេងល្បែងភ្នាល់; ៤ – សុខព្រោះមានចិត្តស្លូតត្រង់ មិនចេះធ្វើអំពើអាក្រក់ដោយហេតុមិនសេពគប់រកជនពាល ។

ឯការគប់រកជនពាលអាក្រក់ នាំឲ្យចេះចំណេះអាក្រក់ ព្រោះមនុស្សពាលមិនដែលនាំឲ្យប្រព្រឹត្តល្អទេ មិនស្គាល់ហេតុនាំឲ្យបានសុខ ស្ដាប់ពាក្យត្រូវមិនសូវបាន, បើអ្នកដែលទៅសេពគប់ផងនោះ មិនចេះលេងស្រី នាំឲ្យចេះលេង, មិនចេះសេពសុរា នាំឲ្យចេះ, មិនចេះលេងល្បែងភ្នាល់ នាំឲ្យចេះលេង, រហូតដល់ទៅនាំឲ្យចេះដើរលេងយប់, បោកប្រាស់បំបាត់ប្រវ័ញ្ចគេ ឆក់ដល់ចេះលួចប្លន់កាប់សម្លាប់គេក៏សឹងមាន; ត្រូវនឹងពុទ្ធភាសិតថា “អសេវនា ច ពាលានំ ការមិនគប់រកពួកជនពាល ជាមង្គលដ៏ប្រសើរ” ។ អ្នកដែលបានវៀរចាកអំពើអាក្រក់ដូចពោលមកហើយនេះ ទុកដូចជាអ្នកបានបណ្ដុះប្រយោជន៍ដ៏ធំទូលាយចំពោះខ្លួនផង ទុកសម្រាប់ប្រទេសជាតិឲ្យបានចំរើនទៅខាងអនាគតផង ។ សេចក្ដីសុខទុក្ខទាំងនេះកើតមកអំពីកម្មផ្ទាល់ខ្លួនពិតៗ ។ ការលះបង់អបាយមុខមានប្រយោជន៍ធំទូលាយក្រៃពេក ដែលពោលមកនេះជាសេចក្ដីសង្ខេប ។ អ្នកប្រាជ្ញជាន់ខ្ពស់ដែលមានឈ្មោះចុះទុកជាប់គង់ប្រវត្តិសាស្ត្រក្នុងលោកតរៀងមកដរាបដល់សព្វថ្ងៃនេះក្ដី ដែលកំពុងមានសព្វថ្ងៃនេះក្ដី កាលបើលោកគិតប្រកបការណាមួយជា

ប្រយោជន៍ខ្លួនទីប្រទេសជាតិជាដើម សុទ្ធតែលោកលះអបាយមុខទាំង ៤ នេះចោលចេញស្រឡះ ទើបធ្វើការនោះបានសម្រេចដូចបំណង ។

មិនត្រឹមតែប៉ុណ្ណោះដែលហៅថាសាសនាបរិសុទ្ធនោះ គឺជាសាសនាអាចញ៉ាំងលោកឲ្យលឿនទៅកាន់សេចក្ដីចំរើន ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីថោកទាបមាននរកជាដើម ឲ្យលោកបានសេចក្ដីសុខស្ងប់ ទាំងធ្វើឲ្យអ្នកជឿស្ដាប់កាន់តាម បានប្រទះប្រយោជន៍សេចក្ដីចំរើនដោយភោគ-សម្ប័ទ បញ្ញាសម្ប័ទ កេរ្តិ៍ឈ្មោះយសស័ក្តិតាមសមគួរ មិនមែនសំដែងប្រាប់ឲ្យមនុស្សសត្វដេកទម្រន់ចាំសំណាងពីព្រេងនាយតែម្យ៉ាងទេ ដូចពុទ្ធភាសិតមានដើមថា សុស្សូសំ លភតេ បញ្ញំ អ្នកមានប្រាជ្ញបេះចំណេះវិជ្ជាគ្រប់យ៉ាងបានមកពីប្រឹងរៀនស្ដាប់ទន្ទេញ មិនធ្វេសប្រ-ហែសក្នុងការរៀនសូត្រ; ឧដ្ឋាតា វិន្ទតេ ធនំ អ្នកមានទ្រព្យធនគ្រប់គ្រាន់ មកពីរវៀសរវៃប្រឹងរកប្រឹងធ្វើមិនខ្ជិល ។ សេចក្ដីដែលសំដែងមកប៉ុណ្ណោះតាមលំអានព្រះពុទ្ធសាសនា ជាសាសនាប្រាប់ផ្លូវប្រតិបត្តិយ៉ាងកណ្ដាល មិនឲ្យសត្វកាន់ឆាកធ្លាក់ទៅលើផ្លូវប្រតិបត្តិខ្វេង ដែលហៅថា អណ្ដាបដិបទា សេចក្ដីប្រតិបត្តិដ៏ណាមក ឬអមទាំងនោះឡើយ មានទំនងឲ្យពួកពុទ្ធបរិស័ទនាំគ្នាកាន់តាមសេចក្ដីពេញចិត្តឥតបង្ខិតបង្ខំ ។ ព្រោះហេតុនោះ ទើបអធិប្បាយថាជាសាសនាស្អាងលោកឲ្យរុងរឿង ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីទាប ។